ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

# សេចក្តីអំពាវនាវជាថ្មី

## ចំពោះបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

ដោយសង្កេតឃើញមានការឆ្លងកូវីដ-១៩ ក្នុងអំឡុងពេល ដែលបងប្អូនពលករនៅប្រទេសថៃធ្វើដំណើរវិលត្រឡប់មកវិញដោយលួចលាក់ និងខុសពីបំរាមអាជ្ញាធរថៃនោះ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃសូមអំពាវនាវជាថ្មីដល់បងប្អូនពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃសូមបន្តស្នាក់នៅក្នុងប្រទេសថៃបន្តទៀត និងចៀសវាងចល័តពីកន្លែងមួយទៅកន្លែងមួយ។

គណៈកម្មការសូមបញ្ជាក់ផងដែរថា ក្នុងអំឡុងពេលការរាតត្បាតជំងឺកូវីដ-១៩នេះ អាជ្ញាធរថៃនឹងមិនមានវិធានការច្បាប់ប្រឆាំងនឹងនិយោជក និងពលករបរទេស ដែលបានកំពុងធ្វើការ និងស្នាក់នៅមួយកន្លែងនោះទេ។ ផ្ទុយទៅវិញ បងប្អូនពលករដែលចល័តពីកន្លែងមួយទៅកន្លែងមួយ ឬមានបំណងវិលត្រឡប់មកស្រុកកំណើតវិញ គឺប្រឈមនឹងហានិភ័យខ្ពស់ពីការឃាត់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ចថៃ និងប្រឈមនឹងលទ្ធភាពឆ្លងជំងឺកូវីដ-១៩ ខ្ពស់នៅក្នុងអំឡុងពេលធ្វើដំណើរវិលត្រឡប់នេះ។

សេចក្តីដូចបានជម្រាបខាងលើ សូមបងប្អូនពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃមេត្តារក្សាភាពនឹងនរ និងបន្តស្នាក់នៅមួយកន្លែងដោយពុំទាន់ចាំបាច់ឆ្លងដែនវិលត្រឡប់មកស្រុកកំណើតវិញនោះទេ។ សូមបងប្អូនពលករជឿទុកចិត្តលើសមត្ថភាព និងលទ្ធភាពទប់ស្កាត់ និងព្យាបាលជំងឺកូវីដ-១៩ របស់អាជ្ញាធរថៃ។

គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមបួងសួង និងជូនពរបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃទាំងអស់សូមមានសុខភាពល្អនិងចាកផុតពីជំងឺកូវីដ-១៩ទាំងអស់គ្នា។

ថ្ងៃសុក្រ ២កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១

**រដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការ**

**អ៊ិត សំហេង**